ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

-សំណុំរឿងរដ្ឋប្បវេណីលេខ ០៧
ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨។

-សាលក្រមរដ្ឋប្បវេណីលេខ ០៣ (គ)
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣។

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២៣។

កាលបរិច្ឆេទប្រកាសសាលក្រម នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២៣។

**ចៅក្រម**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង

**ដើមចោទ ៖**

-ឈ្មោះ [redacted] **គង្គាន** ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ មុខរបរ គ្រូបង្រៀន មាន ទីលំនៅសព្វថ្ងៃនៅភូមិ [redacted]។

-មានលោក [redacted] អគ្គលេខ ២៥៨0T ជាមេធាវីតំណាងដោយអាណត្តិ។

-មានលោក [redacted] អគ្គលេខ ១២៧៨ ជាមេធាវីតំណាងដោយអាណត្តិ។

**សហចុងចម្លើយ ៖**

-ឈ្មោះ [redacted] **ស្រីតូច** ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ មុខរបរ កសិករ និងប្តី ឈ្មោះ [redacted] **ម៉ាច់** អាយុ ៣២ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ មុខរបរ កសិករ ទីលំនៅសព្វថ្ងៃ [redacted]។

## អង្គហេតុ និងចំណុចវិវាទ

**ក-ខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖**

-សុំឱ្យប្រគល់ដីទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង។

-សុំឱ្យមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ចុះបញ្ជីកម្មសិទ្ធិនូវដីលំនៅឋានចំនួន ០១ កន្លែង មានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង។

-សាលក្រមនេះ មានអានុភាពអនុវត្តបណ្ដោះអាសន្នបាន។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

**ខ-ដំណើររឿងក្ដី និងចំណុចវិវាទ ៖**

**ខ.១.ការសង្ខេបរឿងក្ដី ៖**

-កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើមចោទឈ្មោះ [redacted] គង្គាន និងសហចុងចម្លើយឈ្មោះ [redacted] ស្រីតូច និងប្ដីឈ្មោះ [redacted] ម៉ាប់ បានចុះកិច្ចសន្យាលក់ទិញដីចំនួន ០១ កន្លែង ដែលមានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ប្រធានការិយាល័យកសិកម្មស្រុកកំពង់ត្រឡាច ក្នុងតម្លៃ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការទិញលក់នេះ ដើមចោទ បានបង់ប្រាក់ចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយរួចហើយ និងបានសន្យាបង់ប្រាក់បង្គ្រប់ថ្លៃលក់ទិញ១០០% (មួយរយភាគរយ) នៅពេលចាប់ផ្ដើមរៀបចំដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអ្នកទិញ ដល់កាលបរិច្ឆេទកំណត់នៃការបង់ប្រាក់បង្គ្រប់ចុងក្រោយ ដើម្បីផ្ទេរកម្មសិទ្ធិមកឱ្យដើមចោទតាមការសន្យានោះ សហចុងចម្លើយបានគេចវេស និងមិនព្រមប្រគល់ដីនេះ ឱ្យដើមចោទវិញទេ។

**ឯកសារជាភស្ដុតាងរួមមាន ៖**

-លិខិតលក់ផ្ដាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦។

-លិខិតផ្ទេរដីលំនៅឋានផ្ដាច់ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២។

**ខ.២.អង្គហេតុដែលគ្មានវិវាទ ៖**

-កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើមចោទឈ្មោះ [redacted] គង្គាន និងសហចុងចម្លើយឈ្មោះ [redacted] ស្រីតូច និងប្ដីឈ្មោះ [redacted] ម៉ាប់ បានចុះកិច្ចសន្យាលក់ទិញដីលំនៅឋានចំនួន ០១ កន្លែង ដែលមានទំហំ ៦ ម៉ែត្រ



Scanned with CamScanner

X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង។ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ប្រធានការិយាល័យកសិកម្មស្រុកកំពង់ត្រឡាច ក្នុងតម្លៃ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការទិញលក់នេះ ដើមចោទបានបង់ប្រាក់ចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយរួចហើយ និងបានសន្យាបង់ប្រាក់បង្គ្រប់ថ្លៃលក់ចំនួន ១០០%(មួយរយភាគរយ)នៅពេលចាប់ផ្ដើមរៀបចំដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអ្នកទិញ។

**ខ.៣.អង្គហេតុដែលមានវិវាទ ៖**

-សហចុងចម្លើយបានទទួលប្រាក់ថ្លៃលក់ដីលំនៅឋានពីដើមចោទចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិករួចហើយ នៅដំណាក់កាលបង់បង្គ្រប់ចុងក្រោយ សហចុងចម្លើយ បានគេចវេស និងមិនព្រមប្រគល់ដីនេះឱ្យទៅដើមចោទនោះទេ ដោយសុំសងប្រាក់វិញ សងរំលោះក្នុងមួយខែចំនួន ៤០០.០០០ (សែសិបម៉ឺន)រៀល តែដើមចោទមិនឯកភាព និងបានដាក់ពាក្យបណ្ដឹងសុំឱ្យប្រគល់ដី និងចុះបញ្ជីផ្ទេរកម្មសិទ្ធិតាមកិច្ចសន្យាលក់ទិញ។

**ខ.៤.ចំណុចវិវាទ ៖**

-ដើមចោទ សុំឱ្យប្រគល់ដីទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ផ្អែកតាមលិខិតលក់ផ្ដាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦។ ប៉ុន្តែ សហចុងចម្លើយមិនព្រមប្រគល់ដីឱ្យទៅដើមចោទនោះទេ។

**ខ.៥.ចំណុចដែលគ្មានវិវាទ ៖**

-គ្មាន។

**ខ.៦.ការអះអាងរបស់គូភាគី ៖**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ នៅដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់កាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២៣ ថា ខ្លួនសូមរក្សានូវលទ្ធផល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០២២ ទុកជាបានការដដែល។ នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលកន្លងមក សហចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានលក់ដីលំនៅឋានមួយកន្លែងមានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង និងមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R៧-០០២៦ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ប្រធានការិយាល័យកសិកម្មស្រុកកំពង់ត្រឡាច និងលិខិតផ្ទេរដីលំនៅឋានផ្ដាច់ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ ឱ្យមកកូនក្ដីខ្លួនឈ្មោះ [redacted] ង្គាន។ ការទិញលក់នេះ

កូនក្តីខ្លួនបានប្រគល់ប្រាក់ចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយរួចហើយ។ ចំពោះប្រាក់ដែលនៅសល់ថ្លៃលក់ កូនក្តីខ្លួនបង់នៅពេលសហចុងចម្លើយអនុវត្តកាតព្វកិច្ចលក់ទិញចប់ (ផ្ទេរកម្មសិទ្ធិ)។ ខ្លួនស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងដែលមានឯកសារដូចជា លិខិតលក់ផ្តាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ , លិខិតផ្ទេរដីលំនៅឋានផ្តាច់ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R៧-0026 ចុះថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២។ ខ្លួនសូមបញ្ជាក់ថា ដីដែលនៅក្នុងប័ណ្ណកម្មសិទ្ធិនេះ មួយផ្នែកបានលក់ទៅឱ្យឈ្មោះ ហ៊ីង គប្បី ត្រូវជាបងស្រីរបស់កូនក្តីខ្លួនរួចហើយផងដែរ។

-សហចុងចម្លើយឈ្មោះ [redacted] ស្រីតូច បានថ្លែងការណ៍ថា ខ្លួនពិតជាបានលក់ដីឱ្យឈ្មោះ [redacted] គង្គាន ពិតប្រាកដមែន លក់ក្នុងតម្លៃ ២០.០០០(ពីរម៉ឺន)ដុល្លាអាមេរិក កាលនោះគាត់បានប្រគល់ប្រាក់ឱ្យមកខ្លួនបានចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លាអាមេរិក ពេលធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិឈ្មោះ [redacted] គី ត្រូវជាយាយរបស់ប្តីខ្លួនបានបដិសេធមិនឱ្យលក់ដីនេះវិញ ហើយខ្លួនបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] គង្គាន បានចំនួន ១.០០០ (មួយពាន់)ដុល្លាអាមេរិក។ សព្វថ្ងៃនេះ ខ្លួនមិនព្រមប្រគល់ដីទៅឱ្យឈ្មោះ [redacted] គង្គាន តាមលិខិតលក់ទិញនោះទេ ខ្លួនសុំប្រគល់ប្រាក់ជូនគាត់វិញ ដោយសុំបង់ក្នុងមួយខែចំនួន ១០០(មួយរយ)ដុល្លារអាមេរិក។

## សំអាងហេតុ

១-លោក [redacted] មេធាវី តំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ និងអះអាង នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់ថា សុំឱ្យសហចុងចម្លើយប្រគល់ដីទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង និងសុំឱ្យមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ចុះបញ្ជីជាកម្មសិទ្ធិនូវដីលំនៅឋានចំនួន ០១ កន្លែង មានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង និងសុំឱ្យសាលក្រមនេះ មានអានុភាពអនុវត្តបណ្តោះអាសន្នបាន និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។ ដោយហេតុថា កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើមចោទឈ្មោះ [redacted] គង្គាន និងសហចុងចម្លើយឈ្មោះ [redacted] ស្រីតូច និងប្តីឈ្មោះ [redacted] ម៉ាប់ បានចុះកិច្ចសន្យាលក់ទិញដីលំនៅឋានចំនួន ០១ កន្លែង ដែលមានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ប្រធានការិយាល័យកសិកម្មស្រុកកំពង់ត្រឡាច ក្នុងតម្លៃ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការទិញលក់នេះ ដើមចោទបានបង់ប្រាក់ចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយរួចហើយ និងបានសន្យាបង់ប្រាក់បង្គ្រប់ថ្លៃលក់ទិញសរុបចំនួន ១០០% (មួយរយភាគរយ) នៅពេលចាប់ផ្តើមរៀបចំផ្ទេ



Scanned with CamScanner

ណើរការនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអ្នកទិញ។ ពេលដល់កាលបរិច្ឆេទកំណត់នៃការបង់ប្រាក់បង្គ្រប់ចុងក្រោយ ដើម្បីចាប់ផ្តើមរៀបចំដំណើរការផ្ទេរកម្មសិទ្ធមកឱ្យកូនក្តីខ្លួនតាមការសន្យាសហចុងចម្លើយបានគេចវេស និងមិនព្រមប្រគល់ដីនេះឱ្យកូនក្តីខ្លួនឡើយ។ ការរំលោភបំពានកាតព្វរបស់សហចុងចម្លើយនេះបានធ្វើឱ្យកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ មិនអាចអនុវត្តបាន និងធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ។ ខ្លួនសូមបញ្ជាក់ថា ផ្អែកតាមលិខិតផ្ទេរដីលំនៅឋានផ្តាច់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ គឺឈ្មោះ [redacted] គឺ (ត្រូវជាជីដូន) បានផ្ទេរមកឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ស្រីតូច រួចហើយ ហើយសហចុងចម្លើយឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ស្រីតូច បានលក់ដីនេះ ឱ្យមកកូនក្តីខ្លួនតាមលិខិតលក់ផ្តាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ព្រមទាំងបានប្រគល់ លិខិតផ្ទេរដីលំនៅឋានផ្តាច់ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ មកកូនក្តីរបស់ខ្លួនកាន់កាប់ថែមទៀត។ សេចក្តីថ្លែងការណ៍ និងការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ គប្បីតុលាការពិចារណា។

២-សហចុងចម្លើយឈ្មោះ [redacted] ស្រីតូច បានធ្វើសេចក្តីថ្លែងការណ៍ និងអះអាងថា ខ្លួនពិតជាបានលក់ដីឱ្យឈ្មោះ [redacted] គង្គាន ពិតប្រាកដមែន លក់ក្នុងតម្លៃ ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក កាលនោះគាត់បានប្រគល់ប្រាក់ឱ្យមកខ្លួនបានចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លាអាមេរិក ពេលធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិឈ្មោះ [redacted] គឺ ត្រូវជាយាយរបស់ប្តីខ្លួនបានបដិសេធមិនឱ្យលក់ដីនេះវិញ ហើយខ្លួនបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] គង្គាន បានចំនួន ១.០០០(មួយពាន់)ដុល្លាអាមេរិក។ សព្វថ្ងៃនេះ ខ្លួនមិនព្រមប្រគល់ដីទៅឱ្យឈ្មោះ [redacted] គង្គាន តាមលិខិតលក់ទិញនោះទេ ខ្លួនសុំប្រគល់ប្រាក់ជូនគាត់វិញ ដោយសុំបង់ក្នុងមួយខែចំនួន ១០០(មួយរយ)ដុល្លារអាមេរិក។ សេចក្តីថ្លែងការណ៍ និងការអះអាងរបស់សហចុងចម្លើយ គប្បីតុលាការពិចារណា។

៣-តាមលិខិតផ្ទេរដីលំនៅឋានផ្តាច់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឃើញថា ឈ្មោះ [redacted] គី ភេទស្រី អាយុ ៦៩ ឆ្នាំ ត្រូវជាជីដូន របស់សហចុងចម្លើយ បានលក់ដីចំនួន ០១ កន្លែង ដែលមានទំហំ ២៨,៣០ ម៉ែត្រ X ៦,១០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវក្រាំងល្វាសាលាលេខប្រាំ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ធេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ទៅឱ្យឈ្មោះ [redacted] ម៉ាប់ និងប្រពន្ធឈ្មោះ [redacted] ស្រីតូច ប្រាកដមែន។

៤-តាមលិខិតលក់ផ្តាច់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឃើញថា សហចុងចម្លើយឈ្មោះ [redacted] ម៉ាប់ និងប្រពន្ធឈ្មោះ [redacted] ស្រីតូច ពិតជាបានលក់ដីចំនួន ០១ កន្លែង ទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវលំកៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ធេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ឱ្យទៅឈ្មោះ [redacted] គង្គាន ប្រាកដមែន។

៥-ផ្អែកតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ, ការអះអាងរបស់ស

ហាចុងចម្លើយ និងភស្តុតាងជាឯកសារនានានៅក្នុងសំណុំរឿង ឃើញថា ដើមចោទ និងសហចុងចម្លើយ ពិតជាបានបង្កើតកិច្ចសន្យាទិញលក់អចលនវត្ថុ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ នូវដីចំនួន ០១ កន្លែង ទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹង ថ្នល់កៅស៊ូ ខាងត្បូងទល់នឹងឈ្មោះ [redacted] ទ្រី ខាងកើតទល់នឹងឈ្មោះ ហ៊ីង គន្ធី និងខាងលិចទល់នឹងឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ប្រាកដមែន។

៦-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានបញ្ជាក់ថា ដើមចោទបានទិញដីពីសហចុងចម្លើយដែលមានតម្លៃសរុប ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយដើមចោទបានបង់ប្រាក់ចំនួន ១១.២០០ (មួយម៉ឺនមួយពាន់ពីររយ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយរួចហើយ និងប្រាក់ដែលនៅសល់ត្រូវឱ្យនៅពេលចុះបញ្ជីផ្ទេរកម្មសិទ្ធិរួច។ ដូច្នេះ គប្បីឱ្យដើមចោទបង់ប្រាក់ថ្លៃលក់ទិញ ចំនួន ៨.៨០០(ប្រាំបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក ឱ្យសហចុងចម្លើយ តាមបញ្ញត្តិមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណី។

៧-តាមការអះអាងរបស់សហចុងចម្លើយ បានបញ្ជាក់ថា ខ្លួនលក់ដីឱ្យទៅដើមចោទមានតម្លៃសរុប ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយដើមចោទបានប្រគល់ប្រាក់ឱ្យចំនួន ៩.០០០(ប្រាំបួនពាន់) ដុល្លារអាមេរិក រួចហើយ ពេលធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិឈ្មោះ [redacted] គឺ ត្រូវជាយាយរបស់ប្តីខ្លួនបដិសេធមិនឱ្យលក់ដីនេះវិញ ហើយខ្លួនប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] គង្គាន ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមរិក។ ខ្លួនមិនព្រមប្រគល់ដីនេះឱ្យឈ្មោះ [redacted] គង្គាន តាមលិខិតលក់ទិញទេ ដោយសុំប្រគល់ប្រាក់ជូនគាត់វិញ ដោយសុំបង់ចំនួន ១០០(មួយរយ) ដុល្លារអាមេរិក ក្នុងមួយខែ។ តុលាការយល់ឃើញថា សហចុងចម្លើយមានគំនិតទុច្ចរិត ដើម្បីគេចវេសមិនព្រមប្រគល់ដីឱ្យដើមចោទវិញ ការធ្វើបែបនេះ បណ្តាលឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ដើមចោទយ៉ាងធ្ងន់ធ្ងរ។ ត្រង់ចំណុចនេះ គប្បីតុលាការពិចារណា។

៨-តាមបញ្ញត្តិមាត្រា ៥៣០ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា អ្នកលក់មានករណីកិច្ច ត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ ត្រូវប្រគល់វត្ថុដែលបានលក់ ត្រូវថែរក្សាទុកនូវវត្ថុដែលបានលក់ រហូតដល់ពេលប្រគល់ ព្រមទាំងប្រគល់លិខិតផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ចំពោះអ្នកទិញ តាមកិច្ចសន្យា។ ដូច្នេះ គប្បីសហចុងចម្លើយឈ្មោះ [redacted] ស្រីតូច និងឈ្មោះ [redacted] ម៉ាប់ ផ្ទេរកម្មសិទ្ធិនូវដីដែលជាកម្មវត្ថុ នៃកិច្ចសន្យាលក់ទិញឱ្យដើមចោទឈ្មោះ [redacted] គង្គាន។

៩-តាមកិច្ចសន្យាលក់ទិញ (អចលនវត្ថុ) គឺមិនទាន់បានផ្ទេរកម្មសិទ្ធិនោះទេ ដូច្នេះ គប្បីតុលាការសម្រេចអនុញ្ញាតឱ្យមន្ត្រីជំនាញធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុចំនួន ០១ កន្លែង ទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹង ថ្នល់កៅស៊ូ ខាងត្បូងទល់នឹងឈ្មោះ [redacted] ទ្រី ខាងកើតទល់នឹងឈ្មោះ [redacted] គន្ធី និងខាងលិចទល់នឹងឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមានម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] ប៊ុង និងនាងឈ្មោះ [redacted] ភី ឱ្យមកឈ្មោះ [redacted] គង្គាន ជាម្ចាស់កម្មសិទ្ធិវិញ។



Scanned with CamScanner

១០-អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ បានស្នើសុំឲ្យតុលាការសម្រេចអំពីអានុភាពអនុវត្ត ជាបណ្ដោះអាសន្នបានត្រង់ចំណុចទី២ នៃសេចក្ដីសម្រេចបញ្ចប់ តុលាការយល់ឃើញថា ការស្នើសុំនេះ មិនមានភាពចាំបាច់ ដូច្នេះ តុលាការមិនលើកយកមកពិចារណាឡើយ។

១១-ចំពោះប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ស្របតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] ស្រីតូច អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ មានទីលំនៅសព្[redacted] ប្រគល់ដីលំនៅឋាន ០១ កន្លែង ទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ[redacted] ទ្រី ខាងកើតទល់ឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ឲ្យទៅដើមចោទឈ្មោះ [redacted] គង្គាន ជាកម្មសិទ្ធិ ផ្អែកតាមលិខិតលក់ផ្ដាច់ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦។

២-បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] គង្គាន បង់ប្រាក់បង្គ្រប់ថ្លៃលក់ទិញចំនួន ៨.៨០០ (ប្រាំបីពាន់ប្រាំបីរយ) ដុល្លារអាមេរិក ទៅឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រីតូច និងឈ្មោះ [redacted] ម៉ាប់។

៣-អនុញ្ញាតឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយពុះបំបែកក្បាលដីលើដីលំនៅឋាន ០១ កន្លែង ដែលមានទំហំ ៦ ម៉ែត្រ X ២៨ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ថ្នល់កៅស៊ូ ខាងត្បូងទល់ឈ្មោះ [redacted] ទ្រី ខាងកើតឈ្មោះ [redacted] គន្ធី និងខាងលិចទល់ឈ្មោះ [redacted] ឆេន មានទីតាំងនៅភូមិ ការអត ឃុំ ពានី ស្រុក កំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ដីដែលមានប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ R7-0026 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ចេញដោយប្រធានការិយាល័យស្រុកកំពង់ត្រឡាច។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ឆ្នាំង,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ឆ្នាំង,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]